ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៤៣៤.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៩៣ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥
- យោងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- **ឯកឧត្តម** | **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- **ឯកឧត្តម** | **អ៊ុំ មាន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- **ឯកឧត្តម** | **ម៉ៅ ហុងលី** | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- **ឯកឧត្តម** | **ឱក ម៉េង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- **ឯកឧត្តម** | **គឹម ទូច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៦- **ឯកឧត្តម** | **អ៊ឹម កុច** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- **ឯកឧត្តម** | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- **ឯកឧត្តម** | **ញឹម ម៉ូយ៉ាន** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៩- **ឯកឧត្តម** | **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- **លោកជំទាវ** | **ជួញ សុនៃ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិកា |
| ១១- **ឯកឧត្តម** | **លេង ផាលី** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- **លោកជំទាវ** | **ញ៉ែម មរកត** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១៣- **ឯកឧត្តម** | **គិត សេង** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤- **ឯកឧត្តម** | **គឹម សន្តិភាព** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៥- **ឯកឧត្តម** | **កើត ម៉ៀច** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៦- **ឯកឧត្តម** | **មាស ម៉ូរ៉ា** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១៧- **ឯកឧត្តម** | **អិន អេម** | អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៨- **ឯកឧត្តម** | **សាន វឌ្ឍនា** | អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ១៩- **ឯកឧត្តម** | **ជា ឧត្តី** | អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២០- **លោកជំទាវ** | **ស្រី ស៊ីយុត** | អគ្គពិនិត្យនៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ២១- **ឯកឧត្តម** | **តូច ចាន់នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២២- **ឯកឧត្តម** | **ជុប សំអាត** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២៣- **ឯកឧត្តម** | **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២៤- **លោក** | **ឆែ លីឌីន** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៥- **លោក** | **ថូ សំណាង** | អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ២៦- | **ឯកឧត្តម ប៉ា សុជាតិវង្ស** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ២៧- | **ឯកឧត្តម ឃឹម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ២៨- | **ឯកឧត្តម ច័ន្ទ សុផល** | អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ២៩- | **ឯកឧត្តម លន់ លឹមថៃ** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| ៣០- | **ឯកឧត្តម យន្ត មីន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ៣១- | **ឯកឧត្តម ម៉ៅ ធនិន** | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ៣២- | **ឯកឧត្តម អ៊ុត សំអន** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| ៣៣- | **ឯកឧត្តម ឈួរ ច័ន្ទឌឿន** | អភិបាលនៃគណៈអធិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៣៤- | **ឯកឧត្តម វ៉ី សំណាង** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៣៥- | **ឯកឧត្តម ជា សុមេធី** | អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ៣៦- | **ឯកឧត្តម ម៉ែន វិបុល** | អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| ៣៧- | **ឯកឧត្តម សរ ចំរុង** | អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ៣៨- | **ឯកឧត្តម ម៉ុម សារឿន** | អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៣៩- | **ឯកឧត្តម អ៊ុំ ម៉ារ៉ា** | អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ៤០- | **ឯកឧត្តម ស្វាយ សំអ៊ាង** | អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៤១- | **ឯកឧត្តម ថង សាវុន** | អភិបាលនៃគណៈអភិបាលខេត្តរតនៈគិរី | សមាជិក |
| ៤២- | **ឯកឧត្តម សួន បវរ** | អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ៤៣- | **ឯកឧត្តម ស ថាវី** | អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ៤៤- | **ឯកឧត្តម ខាន់ ចេស្តា** | អភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ៤៥- | **ឯកឧត្តម ប៊ុន លើត** | អភិបាលនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| ៤៦- | **ឯកឧត្តម ឡាយ វណ្ណៈ** | អភិបាលនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ៤៧- | **ឯកឧត្តម ម៉ៅ ភិរុណ** | អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ៤៨- | **ឯកឧត្តម ប្រាជ្ញ ច័ន្ទ** | អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ៤៩- | **ឯកឧត្តម អ៊ើត សុធា** | អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ៥០- | **ឯកឧត្តម អ៊ែន សត្ថា** | អភិបាលនៃគណៈអភិបាលខេត្តកែប | សមាជិក |

**មាត្រា២.-**

ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពណាមួយ នៅក្នុងមាត្រា១ ក្រសួង ស្ថាប័ន និងអង្គភាពសាមី ត្រូវបញ្ជូនសមាសភាពថ្មី មកប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ សម្រាប់ជំនួស។

**មាត្រា៣.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានសិទ្ធិចាត់តាំងអភិបាលរងទទួលបន្ទុកគណៈកម្មការសម្រាប់អនុវត្តគោលនយោបាយជាតិមុខរបរ និងការងាររាជធានី ខេត្ត ជាតំណាង ដើម្បីចូលរួមប្រជុំជំនួស។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា១ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ